**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០២៣១/២០ ក.អ.ជ

ថ្ងៃ ចន្ទ ២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ ២០២០
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ដើមឆ្នាំ២០២០ នេះ ក្រសួងបានបិទបញ្ចប់ផែនការសកម្មភាពឆ្នាំ ២០១៩ តាមរយៈសន្និបាតបូកសរុបការងារឆ្នាំ ២០១៩ និងកំណត់ទិសដៅការងារឆ្នាំ ២០២០ កាលពីចុងខែមករា នេះប្រកបដោយជោគជ័យគួរជាទីមោទនៈ។ ផ្លែផ្កានៃការអនុវត្តសកម្មភាពការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទកំពុងជំរុញលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជនក្នុងសហគមន៍ជនបទកាន់តែល្អប្រសើរឡើងជាលំដាប់ ជាអាទិ៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទតភ្ជាប់ខ្វាត់ខ្វែងទូទាំងប្រទេស សម្រួលដល់ការធ្វើដំណើរ អាជីវកម្ម សេវាកម្ម ផលិតកម្មកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស ហើយបានចូលរួមកាត់បន្ថយថ្លៃដើមផលិត ។ ការថែទាំសុខភាពអនាម័យខ្លួនប្រាណ ការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាលកំពុងក្លាយជាចលនាចូលរួមយ៉ាងសកម្មពីគ្រប់ទិសទី ទាំងមន្រ្តីរាជការ អាជ្ញាធរដែនដី រហូតដល់ប្រជាជនក្នុងសហគមន៍ ។ ការបរិភោគទឹកស្អាត ការទុកដាក់ទឹកដោយសុវត្ថិភាព និងការប្រើប្រាស់ប្រភពទឹកត្រូវបានក្រសួងយកចិត្តទុកដាក់ផ្សព្វផ្សាយដល់មូលដ្ឋានជនបទគ្រប់ខេត្ត-ក្រុង ។ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទត្រូវបានក្រសួងយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីគិតគូរពីការបង្កើនប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាជននៅជនបទ តាមរយៈការបង្កើនសមត្ថភាពផលិតកម្មកសិកម្ម និងមិនមែនកសិកម្ម បង្កើតជំនួញខ្នាតតូច និងមធ្យម តាំងពិព័រណ៍ផលិតផលខ្មែរ សាងសង់ផ្សារជនបទ និងផ្តល់ឥណទានដោយអត្រាការប្រាក់តិចជូនប្រជាជនដើម្បីបង្កើតអាជីវកម្មគ្រួសារ ។ល។

ក្រៅពីការងារជំនាញ ក្រសួងបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូរជាទ្វេភាគី ពហុភាគី អាស៊ាន និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀតដែលជួយគាំទ្រដល់គោលនយោបាយ និងយុទ្ធសាស្រ្តក្រសួងឲ្យទទួលបានជោគជ័យ ។

លទ្ធផលដែលក្រសួងសម្រេចបានប្រចាំខែមករា ឆ្នាំ ២០២០ នេះមានដូចខាងក្រោម៖

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

កម្មវិធីទាំង៤ របស់ក្រសួងដែលបានអនុម័តកាលពីឆ្នាំ ២០១៩ ត្រូវបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

២០២០នេះ ដើម្បីសម្រេចគោលដៅនៃចក្ខុវិស័យជំរុញឲ្យមានការផ្លាស់ប្តូរជីវភាពរស់នៅដោយផ្ទាល់របស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។ ក្នុងខែមករានេះ ក្រសួងទើបចាប់ផ្តើមដំណើរការសកម្មភាពបានតិចតួចប៉ុណ្ណោះ ។

**២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ**

**២.២.១.ការងាររដ្ឋបាល និងបុគ្គលិក**

ដោយគិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៧៨៩ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែធ្នូ ឆ្នាំ២០១៩ គឺមានការកើនឡើងចំនួន ០៩ នាក់ ដោយការផ្ទេរក្របខណ្ឌចូល។ ក្រសួងបានទទួលលិខិតចូលចំនួន ១១៤ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ៦៥ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ៣២ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១៨៦ ច្បាប់ ។

**២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

ក្នុងខែមករា នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២០ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ១ ១៤៣ ៨៧៥ ១០០ រៀល ស្មើនឹង ១% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ០០ រៀល ស្មើនឹង ០០% នៃច្បាប់ថវិកា ។

**២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចូលរួមប្រជុំស្តីពីសេចក្តីព្រាងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ឆ្នាំ២០១៩-២០២៥ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ែន ជារុង្គ** អគ្គនាយកដ្ឋានវិនិយោគ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមប្រជុំជាមួយក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)ដឹកនាំដោយ លោក អ៊ុច ចំរើន តំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា ដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ និងការបញ្ជ្រៀបយេនឌ័រ និងភាពក្រីក្រចូលក្នុងផែនការយុទ្ធសាស្ត្រក្រសួង
- ចូលរួមកិច្ចប្រជុំ Kick off Meeting នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដឹកនាំដោយ **ឯកឧត្តម អ៊ុង លុយណា** អគ្គលេខាធិការរងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយជំនាញការមកពីសហគមន៍អឺរ៉ុប (EU) ស្តីពីការពិភាក្សាលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាកម្មវិធី (PB) កិច្ចដំណើរការ ការអនុវត្តថវិកា ការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើ ការអនុវត្តផែនការ និងបន្ទាប់មកជំនាញការ EU នឹងជួបផ្ទាល់ជាមួយអង្គភាពថវិកាមួយចំនួន របស់ក្រសួង អភិវឌ្ឍន៍ជនបទនៅខែកុម្ភៈ ដើម្បីស្វែងយល់ពីកិច្ចអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន ។

២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ០៣ ដោយប្រគល់ទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់ពី ឆ្នាំ២០២០ តទៅ ។

២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- ជួបពិភាក្សាជាមួយតំណាង ADB និង EU លើការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី ការអនុវត្តផែនការ និងរបាយការណ៍វឌ្ឍនភាពរបស់ក្រសួង
- ពិនិត្យ កែសម្រួល និងផ្តល់យោបល់លើឯកសារផែនការសកម្មភាព ASEAN-CANADA ដោយបានបន្ថែមសកម្មភាពចំនួន ០៣ ស្តីពីការអភិវឌ្ឍជនបទចូលក្នុងនោះ
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងសៀវភៅស្ថិតិស្តីពីទំនាក់ទំនង ASEAN-CHINA ឆ្នាំ ២០១៨
- រៀបចំរបាយការណ៍កិច្ចសហប្រតិបត្តិការ ទ្វេភាគី CAMBODIA-BANGLADESH
- រៀបចំសិក្ខាសាលាស្តីពីកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ឆ្នាំ ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមអនឡាញ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ២៥ នៅទីស្តីការក្រសួងផែនការ
- រៀបចំរបាយការណ៍សូចនាករថវិកាកម្មវិធីប្រចាំឆ្នាំ២០១៩
- ចូលរួមសិក្ខាសាលា ស្តីពីសេចក្តីព្រាងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០១៩-២០២៥
- ផ្សព្វផ្សាយរបាយការណ៍ប្រចាំខែ ត្រីមាស ប្រចាំឆ្នាំ និងផែនការសកម្មភាព ក្នុងគេហទំព័រក្រសួងជាសាធារណៈ
- តាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០២ គឺ ខេត្តសៀមរាប និងកំពង់ធំ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់លិខិតគាំទ្រកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការ ជូនអង្គការចំនួន ០២ គឺ អង្គការការីតាសកម្ពុជា និងអង្គការស៊ី ប៊ី អិន

- បានផ្តល់លិខិតគាំទ្រសុំអន្តរាគមន៍ដើម្បីនាំចូលរថយន្តថ្មីចំនួន ០១ គ្រឿងជូនអង្គការមុស្លីមអេដកម្ពុជា
- បានចុះពិនិត្យការងារជាក់ស្តែងរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តរតនៈគិរី ខេត្តមណ្ឌលគិរី និងខេត្តសៀមរាប ។

២.២.៦. ការងារអធិការកិច្ច និងសវនកម្ម
- ចូលរួមកិច្ចប្រជុំពិនិត្យរបាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងលើកទិសដៅការងារ ឆ្នាំ ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍
- គម្រោងថែទាំខួប និងថែទាំប្រចាំ សម្រាប់ឆ្នាំ ២០២០ កំពុងដំណើរការនីតិវិធី
- បន្តការតាមដានត្រួតពិនិត្យវាយតម្លៃ និងសុពលភាពគម្រោងអនុវត្តក្នុងឆ្នាំ ២០១៩
- មន្ទីរពិសោធន៍កំពុងបន្តបណ្តុះបណ្តាលការងារតេស្ត DCP នៅការដ្ឋានដល់ប្រធានផ្នែក និងមន្ត្រីបច្ចេកទេស ចំនួន ១៧ នាក់ ស្រី ០២ នាក់
- មន្ទីរពិសោធន៍កំពុងបន្តបណ្តុះបណ្តាលការងារតេស្តកៅស៊ូ ( Softening Point of Bitumen ) ជូនប្រធានផ្នែក និងមន្ត្រីបច្ចេកទេសចំនួន ១៧ នាក់ ស្រី ០២ នាក់ ដើម្បីដឹងនូវចំណាត់ថ្នាក់កៅស៊ូ និងទំនាក់ទំនងនូវលំហូរកៅស៊ូទៅនឹងសីតុណ្ហភាព។

២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ
- បានចុះពិនិត្យការតភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ នៅស្រុកល្វាឯម ខេត្តកណ្តាល និង ស្រុកពោធិ៍រៀង ខេត្តព្រៃវែង
- បានចុះត្រួតពិនិត្យ និងវាយតម្លៃអណ្តូងស្នប់ ១០០% ដែលប្រើប្រាស់ថវិកាជាតិឆ្នាំ ២០១៩ នៅខេត្តកែប
- បានដឹកនាំកិច្ចប្រជុំអនុក្រុមវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ ដើម្បីរៀបចំកម្មវិធីអង្គវិប្បសនាក្រុមការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ និងទិវាទឹកពិភពលោក ។

២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ
- បានចុះជ្រើសរើសភូមិគោលដៅ ដើម្បីអនុវត្តគម្រោងជំរុញការផ្តល់សេវាអនាម័យជនបទឆ្នាំ២០២០ នៅខេត្តគោលដៅចំនួន១៣ គឺ ខេត្តក្រចេះ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ ប៉ៃលិន ព្រះសីហនុ សៀមរាប កោះកុង កែប ឧត្តរមានជ័យ ព្រះវិហារ និងខេត្តស្វាយរៀង
- បានចុះចែកកន្ទោដល់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ចំនួន ១០០ កន្ទោ ដែលមានអ្នកចូលរួមចំនួន ១៥០ នាក់ក្នុងសហគមន៍ចំនួន ០៥ នៅសង្កាត់ទួលសង្កែ និងសង្កាត់ស្វាយប៉ាក រាជធានីភ្នំពេញ
- បានសហការជាមួយអង្គការ CRDT ចុះជំរុញការសាងសង់បង្គន់អនាម័យនៅភូមិចំនួន ០៣ ឃុំសៀមប៉ាង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

- បានសហការជាមួយ អង្គការ Plan International Cambodia ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF នៅ ក្នុងស្រុកអូរឬស្សីជុំ ខេត្តរតនគិរី ជាលទ្ធផលមានភូមិចំនួន ០៤ បានជាប់ជាភូមិ ODF ។

២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- រៀបចំផែនការកម្មវិធីរបស់ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាន ឆ្នាំ ២០២០
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានរៀបចំឯកសារ និង កំណត់ឃុំគោលដៅ សម្រាប់ផ្សព្វផ្សាយបើកវគ្គសិក្សាថ្មី ឆ្នាំ ២០២០
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

២.២.១១. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ២៥ នាក់ ស្រី ០៤ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០១ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៧៥ នាក់ ស្រី ០៥ នាក់
- បានរៀបចំឯកសារលិខិតចាត់បញ្ជូនមន្ត្រី ចំនួន ០២ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាល ចំនួន ០២ លើក
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១២ ខេត្ត រួមមាន ៖ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ បានរៀបចំឯកសារមួយចំនួន និងធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជ្រើសរើសសិក្ខាកាមនៅតាមតំបន់គោលដៅ ព្រមទាំងធ្វើការផ្សព្វផ្សាយតាមវិទ្យុ FM របស់ខេត្ត សម្រាប់បើកវគ្គថ្មី វគ្គទី ១ ឆមាសទី ១ ឆ្នាំ ២០២០ ។

២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៣ ៩៩៩ ៣៣៩ ១៣៥ រៀល (បីប៊ីលានប្រាំបួនរយកៅសិបប្រាំបួនលានបីរយសាមសិបប្រាំបួនពាន់មួយរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០១៩ ០៦០,៧៤ ដុល្លារអាមេរិក (មួយលានដប់ប្រាំបួនពាន់ហុកសិបដុល្លារនិងចិតសិបបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ២៥២ នាក់ នៅភូមិគោលដៅចំនួន ២៤៤ ភូមិ ១០០ ឃុំ ៣២ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានរៀបចំពិធីតាំងពិព័រណ៍ផលិតផលខ្មែរ "ភូមិខ្ញុំ ផលិតផលខ្ញុំ" នៅខេត្តកំពង់ធំ ចំនួន ០១ លើក រយៈពេល ០២ ថ្ងៃ ដែលមានស្តង់ ចំនួន ៨០ ស្តង់ អ្នកចូលរួមទស្សនាចំនួនប្រមាណ

៣ ៤៩៦ នាក់

- បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែក បច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក្រ ស្ថិតនៅដែសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦ នាក់ ស្រី ៦៤ នាក់ ។

**២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- ប្រជុំរៀបចំផែនការការងារ ស្តីពីការអភិរក្ស និងការអភិវឌ្ឍជនជាតិដើមភាគតិច ជាមួយអង្គការដៃគូ (NGO Forum) ក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ចូលរួមអភិរក្ស ព្រមទាំងថែរក្សាវប្បធម៌ ប្រពៃណីល្អ ទំនៀមទម្លាប់ និងជំនឿរបស់ពួកគាត់ ចង់ឲ្យជនជាតិដើមភាគតិចទទួលបានផលប្រយោជន៍តាមផ្លូវច្បាប់ស្រប់តាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងខែមករា ឆ្នាំ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលបានសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត សរុបចំនួន ០៤ ករណី ក្នុងនោះក្រសួងពុំទាន់បានដោះស្រាយជូនប្រជាពលរដ្ឋនៅឡើយទេ ។

**២.២.១៥. ការងារយេនឌ័រ**

- ចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការតាមដាន និងវាយតម្លៃការអនុវត្តអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ)
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ឧបករណ៍តាមដាន និងវាយតម្លៃពាក់ព័ន្ធសិទ្ធិស្ត្រី និងយេនឌ័រ
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២០ ។

**២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី**

**២.៣.១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២**

គិតត្រឹមដំណាច់ខែមករានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៦៣,៤៧%

- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៦៩,៣៣%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៥២,១៨%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៦១,៣៥%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៥៥,៨៤%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១២៥,៥០ គ.ម សម្រេចបាន ១០០%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ ខ្សែ មានប្រវែងសរុប ១០១,២០ គ.ម សម្រេចបាន ១០០%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ ខ្សែ មានប្រវែងសរុប ៥០ គ.ម សម្រេចបាន ១០០%
- សាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម សម្រេចបាន ៤៧,១១ % ។

**២.៣.២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

គិតត្រឹមដំណាច់ខែមករានេះ គម្រោងបានបញ្ចប់ការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែងសរុប ៩,៩ គ.ម និងកំពុងដំណើរការសាងសង់ផ្លូវក្រាលក្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ចំនួន ០២ ខ្សែ មានប្រវែងសរុប ៣៧,៣០ គ.ម នៅស្រុកមង្គលបូរី និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ សម្រេចបាន ៦៤% ។

**២.៣.៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គិតត្រឹមខែមករានេះ គម្រោងបាន និងកំពុងអនុវត្តចំនួន ៦០ គម្រោង ប្រវែង ១៦៨ ៦៩៤ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១២ ក្នុងនោះបានបញ្ចប់ការងារ បានចំនួន ១៥ គម្រោង ប្រវែងសរុប ៤៤ ៣២០ ម៉ែត្រ នៅខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តពោធិ៍សាត់ ។

**២.៣.៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សង់បង្គន់សាធារណៈ និងអាងត្រងទឹកភ្លៀងសាធារណៈបានចំនួន ១០ កន្លែង និងសាងសង់ថ្នាលហាលលាមក សម្រេចបាន ១០០% នៅខេត្តបន្ទាយមានជ័យ
- ដឹកសម្ភារបង្គន់គ្រួសារចែកជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋបានធ្វើបង្គន់អនាម័យរួចរាល់បានចំនួន ១ ៩៥៨ ខ្នងផ្ទះ និងសាងសង់បង្គន់ ABC សម្រេចបាន ៥% នៅខេត្តបន្ទាយមានជ័យ ។

២.៣.៥. គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation)

- ចុះត្រួតពិនិត្យមើលសមិទ្ធផលនៃគម្រោងជំហានទី១ ការការងារសាងសង់បង្គន់អនាម័យ ចង្រ្កានបច្ចេកទេសជុតអុស ត្រួតពិនិត្យការអនុវត្តបច្ចេកទេសផលិតសាប៊ូតាមគ្រួសារដែលបានបណ្តុះបណ្តាលរួចនៅខេត្តគោលដៅចំនួន០៤ គឺ ខេត្តក្រចេះ ស្ទឹងត្រែង ព្រៃវែង និង ខេត្តកណ្តាល។

២.៣.៦. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍

គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ គឺជាគម្រោងក្រោមហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានថវិកាសរុប ៦២,៥ លានដុល្លារអាមេរិក ក្រោមការគ្រប់គ្រង និងដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គម្រោងនឹងត្រូវធ្វើការស្តាបនាផ្លូវក្រាលកៅស៊ូពីរជាន់ DBST និងប្រភេទផ្លូវបេតុងចំពោះតំបន់មានទឹកលិច ប្រវែងសរុបចំនួន ២៥៥ គីឡូម៉ែត្រ ស្ពាន ប្រវែង ១០០ ម៉ែត្រ ចំនួន ០១ ព្រមទាំងសំណង់សិល្បការ្យជាច្រើនទៀត នៅក្នុងខេត្តគោលដៅរបស់គម្រោងចំនួន ០៦ រួមមាន ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តសៀមរាប។ ក្នុងខែមករានេះ គម្រោងសម្រេចបាន ៖

- បាននិងកំពុងដំណើរការនីតិវិធីដេញថ្លៃ កញ្ចប់ទី ១ សម្រាប់កាស្តាបនាផ្លូវប្រវែង ៥០ គីឡូម៉ែត្រ នៅក្នុងខេត្តកណ្តាល ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង
- គ្រោងនឹងដាក់ដេញថ្លៃ កញ្ចប់ទី ២ សម្រាប់កាស្តាបនាផ្លូវប្រវែង ៤៥ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០២ រួមមាន ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង
- គ្រោងនឹងដាក់ដេញថ្លៃ កញ្ចប់ទី ៣ សម្រាប់កាស្តាបនាផ្លូវប្រវែង ១៦០ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង ។

## ៣. ទិសដៅបន្ត

៣.១. បញ្ហាប្រឈម

- ឧបករណ៍ពិសោធន៍មួយចំនួនពុំទាន់បានបណ្តុះបណ្តាលដល់វិស្វករ និងមន្ត្រីជំនាញ បម្រើការងារនៅមន្ទីរពិសោធន៍
- ទាមទារពេលវេលាវែង ដើម្បីជំរុញការផ្លាស់ប្តូរទម្លាប់របស់ប្រជាជន ក្នុងការប្រតិបត្តិអនាម័យល្អ
- ខ្វះយន្តការគាំទ្រ និងការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះខ្វះទឹកដែលអាចប៉ះពាល់ដល់ស្ថានភាពអនាម័យ
- ទម្លាប់សង្គមក្នុងការបន្ទោរបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)

- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមួយចំនួនមានជីវភាពខ្វះខាត ជាហេតុនាំឲ្យមានការធ្វើចំណាកស្រុកទៅប្រកបមុខរបរនៅប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ ។

### ៣.២. ទិសដៅតាមអង្គភាព

- រៀបចំផែនការវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣
- រៀបចំ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានីខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំងបី គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិ ជំហានទី ១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី ២ ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

ដើមឆ្នាំ២០២០នេះ លទ្ធផលនៃការអនុវត្តផែនការសកម្មភាពនៅមានកម្រិតតិចតួចនៅឡើយ ក្រសួងអភិវឌ្ឍន៍ជនបទទើបបានបិទបញ្ចប់សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងកំណត់ទិសដៅការងារឆ្នាំ ២០២០ រួចហើយ ។ លទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៩ បានបង្ហាញពីមោទនភាពគួរឲ្យកត់សម្គាល់ដែលក្រសួងសម្រេចបានពិសេសការកែទម្រង់ផ្ទៃក្នុងបានល្អតាំងពីរបៀបរបការងារ (កែទម្រង់ស្ថាប័ន) ការរៀបចំយុទ្ធសាស្ត្រ ផែនការថវិកាកម្មវិធី (កែទម្រង់ហិរញ្ញវត្ថុសាធារណៈ) ការ

ផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ ( កែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ) ដែលកាន់តែមានភាពស៊ីជម្រៅជាងមុនពោលគឺតម្រង់ទិសទៅរកការកាត់បន្ថយភាពក្រីក្រ និងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅជនបទ ផ្លាស់ប្តូរផ្នត់គំនិត និងរបៀបរស់នៅឲ្យកាន់តែស៊ីវិល័យ បែបជនបទដើម្បី ជានាឲ្យប្រជាជនរស់នៅដោយផាសុខភាព អនាម័យល្អ បរិស្ថានស្អាត និងមានជីវភាពសមរម្យក្នុងបរិបទសង្គមកម្ពុជាសម័យទំនើបក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**